# ច្បាប់

# ស្តីពី

# ចរាចរណ៍ផ្លូវគោក

**ក្រុមប្រឹក្សារដ្ឋ**

៚

លេខៈ ៦៨ ក្រ

**រ ដ្ឋ ក ម្ពុ ជា**

**ឯករាជ្យ សន្តិភាព សេរីភាព សុភមង្គល**

៚

# ក្រឹត្យ

៚

## ក្រុមប្រឹក្សារដ្ឋ

## នៃ

## រដ្ឋកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃ រដ្ឋកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំរដ្ឋសភា និង ក្រុមប្រឹក្សារដ្ឋ នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៤ ក្រ ចុះថ្ងៃទី១០ ខែ កុម្ភៈ ឆ្នាំ ១៩៨២

## សំរេច

៚

ប្រកាសអោយប្រើច្បាប់ ស្តីពីចរាចរណ៍ផ្លូវគោក ដែលរដ្ឋសភា នៃរដ្ឋកម្ពុជា បានអនុម័តនៅថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ១៩៩១ នាសម័យប្រជុំសាមញ្ញលើកទី ២១ នីតិកាលទី ១ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី ៣១ ខែសីហា ឆ្នាំ ១៩៩១

ជ.ក្រុមប្រឹក្សារដ្ឋ

ប្រធាន

ហត្ថលេខា និង ត្រា : ហេង សំរិន

កន្លែងទទួល :

- ខុទ្ទកាល័យមជ្ឈិមបក្ស
- ខុទ្ទកាល័យរដ្ឋសភា
- ខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រី
- គ្រប់ទីស្តីការរដ្ឋមន្ត្រីនិងស្ថាប័នថ្នាក់ប្រហាក់ប្រហែល
- គ្រប់គណៈកម្មាធិការប្រជាជនខេត្ត ក្រុង
- រ ដ្ឋ កិ ច្ច
- កាលប្បវត្តិ - ឯកសារ

...ដើម្បីចម្លងចែក

...ក្រុមប្រឹក្សារដ្ឋ

ចាន់ វ៉េន

រដ្ឋសភា

រដ្ឋកម្ពុជា

ឯករាជ្យ សន្តិភាព សេរីភាព សុភមង្គល

# ច្បាប់

# ស្តីពី

# ចរាចរណ៍ផ្លូវគោក

## ជំពូកទី ១

## បទបញ្ញត្តិទូទៅ

មាត្រា ១ .- ច្បាប់នេះមានគោលដៅលើកកំពស់កិត្យានុភាព និង ប្រសិទ្ធភាពក្នុងការការពារសុវត្ថិភាពចរាចរណ៍រក្សាសន្តិសុខសាធារណៈ និង របៀបរៀបរយសង្គម ការពារទ្រព្យសម្បត្តិសាធារណៈអាយុជីវិត និង ផលប្រយោជន៍ស្របច្បាប់របស់ជនគ្រប់រូប ព្រមជាមួយនោះ មានគោលដៅអប់រំជនគ្រប់រូបអោយស្រឡាញ់ និង គោរពច្បាប់ អោយចូលរួមប្រឆាំង និង បង្ការបទល្មើសនឹងបទបញ្ញាចរាចរណ៍ ។

មាត្រា ២ .- រាល់អំពើដែលបង្កអោយមានគ្រោះថ្នាក់ចរាចរណ៍ ត្រូវហាមឃាត់ ។

មាត្រា ៣ .- ការរំលោភលើ រូបរាងកាយ កិត្តិយស សេចក្តីថ្លៃថ្នូរ និង សមត្ថកិច្ចរបស់ភ្នាក់ងារតម្រួតចរាចរណ៍ដែលកំពុងបំពេញភារកិច្ច ត្រូវទទួលទោសតាមច្បាប់ ។

មាត្រា ៤ .- ច្បាប់នេះត្រូវអនុវត្តចំពោះការធ្វើចរាចរណ៍លើផ្លូវថ្នល់សាធារណៈទាំងអស់ ។

មាត្រា ៥ .- រដ្ឋកម្ពុជាកំណត់ការធ្វើចរាចរណ៍លើផ្លូវថ្នល់សាធារណៈនៅខាងស្តាំ ដៃរបស់ខ្លួន ។

មាត្រា ៦ .- អ្នកប្រើប្រាស់ផ្លូវសាធារណៈ ត្រូវគោរពអោយបានត្រឹមត្រូវ តាមបទបញ្ញត្តិដែលមានចែងក្នុងច្បាប់នេះ ។

## ជំពូកទី ២

## ចំពោះថ្មើរជើង អ្នកជិះសត្វបង្ហឹកសត្វ

មាត្រា ៧ .- ថ្មើរជើងត្រូវធ្វើចរាចរណ៍នៅលើចិញ្ចើមថ្នល់ ឬ ជាយថ្នល់ ។

ថ្មើរជើងត្រូវឆ្លងកាត់ទ្រូងថ្នល់ តាមគំនូសអង្កត់កាត់ទទឹងទ្រូងថ្នល់ ឬចន្លោះផ្លូវ ច្បោះដែកគោលសំរាប់ថ្មើរជើង ដោយគោរពភ្លើងសញ្ញាចរាចរណ៍ ឬតាមការណែនាំរបស់ភ្នាក់ងារដែលមានសមត្ថកិច្ចប្រចាំការនៅទីនោះ ។ បើផ្លូវគ្មានគំនូសអង្កត់ ឬ ច្បោះដែកគោលទេ ថ្មើរជើងត្រូវឆ្លងកាត់ទទឹងទ្រូងថ្នល់ត្រង់ មិនត្រូវឆ្លងដោយបញ្ឆិតទ្រូងថ្នល់ ឬ ខ្នែងផ្លូវ ចែកជាបួនឡើយ ។

មាត្រា ៨ .- ក្បួនដង្ហែរនានា ក្រុមយោធា នគរបាល កុមារឈានមុខ សិស្ស និស្សិត សិល្បករ ដែលដើរជាពួក ជាក្រុម ដោយមានការចាត់តាំងត្រឹមត្រូវ អាចអនុញ្ញាតអោយដើរ

២ជួរដល់ ៥ ជួរ យោលតាមទ្រូងថ្នល់តូចធំ ហើយត្រូវធានាសណ្តាប់ធ្នាប់ចរាចរណ៍ ។

មាត្រា ៩ .- អ្នកជិះសត្វពាហនៈ ឬ ដឹកសត្វពាហនៈ អ្នកអូស ឬ រុញរទេះ ដែលធ្វើចរាចរណ៍លើផ្លូវថ្នល់សាធារណៈត្រូវគោរពភ្លើង ឬ ផ្លាកសញ្ញាចរាចរណ៍ ឬ តាមការណែនាំរបស់ភ្នាក់ងារដែលចាំពេញភារកិច្ចនៅទីនោះ ។

## ជំពូកទី ៣

## ចំពោះអ្នកបើកយានជំនិះ

មាត្រា ១០ .- ហាមមិនអោយអនីតិជនអាយុតិចជាង ១៦ ឆ្នាំ បើកបរយានយន្តគ្រប់ប្រភេទនៅលើផ្លូវថ្នល់សាធារណៈ ។

មាត្រា ១១ .- អ្នកបើកបរយានជំនិះគ្រប់ប្រភេទ ត្រូវធ្វើចរាចរណ៍តាមចំណែកផ្លូវ កំណត់សំរាប់ប្រភេទយាននិមួយៗ និងត្រូវគោរពតាមគំនូសចរាចរណ៍នៅលើទ្រូងថ្នល់ ភ្លើង ឬ ផ្លាកសញ្ញា និង សញ្ញាដៃអ្នកបញ្ជាចរាចរណ៍ដូចខាងក្រោម :

### ១- គំនូសចរាចរណ៍នៅលើទ្រូងថ្នល់ :

ក- គំនូសបន្ទាត់ចង្អូតពណ៌សដែលពុះចំកណ្តាលទ្រូងថ្នល់ ជាសញ្ញាហាមមិនអោយបរកាត់ ឬ បរជាន់ ។

ខ- គំនូសបន្ទាត់ដាច់ៗពណ៌សដែលពុះចំកណ្តាលទ្រូងថ្នល់ ជាសញ្ញាអនុញ្ញាតអោយបរកាត់ ។

គ- គំនូសបន្ទាត់ដាច់ៗពណ៌លឿង ដែលនៅអមខាងគំនូសបន្ទាត់ចង្អូតពណ៌សដែលពុះចំកណ្តាលទ្រូងថ្នល់ជាសញ្ញាអាចបរកាត់បាន ។

ឃ- នៅតាមផ្លូវដែលមានបន្ទាត់ចង្អូតពណ៌ស នៅកណ្តាលទ្រូងថ្នល់ យានយន្តណានៅខាងគំនូសដាច់ៗអាចបរកាត់បាន ។

ង- គំនូសអង្កន់កាត់ទទឹងទ្រូងថ្នល់ ឬ ផ្លូវបោះដែកគោល ជាសញ្ញាសំរាប់ថ្មើរជើងឆ្លងកាត់ ។

ច- គំនូសបន្ទាត់ចង្អូតពណ៌ស កាត់ទទឹងទ្រូងថ្នល់ នៅពីមុខគំនូសអង្កន់កាត់ទទឹងទ្រូងថ្នល់ ឬ ផ្លូវបោះដែកគោល ជាសញ្ញាអោយយានជំនិះឈប់នៅនឹងកន្លែងនេះ ដើម្បីរង់ចាំថ្មើរជើងឆ្លងផុត ឬ ភ្នាក់ងារសមត្ថកិច្ចអនុញ្ញាតអោយទៅ ឬ មានភ្លើងសញ្ញាអោយទៅ ។

### ២- ភ្លើងសញ្ញា :

ក- ភ្លើងពណ៌ក្រហមជាសញ្ញាឃាត់អោយឈប់ បើគ្មានឧបសគ្គនៅខាងមុខ យានជំនិះដែលនៅខាងស្តាំបំផុត អាចបត់ស្តាំបាន ។

ខ- ភ្លើងពណ៌លឿង ជាសញ្ញាអោយប្រុងប្រយ័ត្ន ។ បើយានជំនិះឆ្លងផុតគំនូសបន្ទាត់កំណត់អោយឈប់នៃផ្លូវបំបែកហើយត្រូវបន្តដំណើរទៅមុខ ។

គ- ភ្លើងពណ៌បៃតង ជាសញ្ញាអនុញ្ញាតអោយធ្វើចរាចរណ៍ ។

ឃ- ភ្លើងភ្លឺបភ្លែតៗ ពណ៌លឿង ជាសញ្ញាអនុញ្ញាតអោយធ្វើចរាចរដោយប្រុងប្រយ័ត្ន និងបន្ថយល្បឿន ។

៣- <u>សញ្ញាដៃនៃអ្នកបញ្ជាចរាចរណ៍</u> :

ក- ដៃម្ខាងលើកបញ្ឈរ ជាសញ្ញាអោយឈប់ ។

ខ- ដៃមួយ ឬ ដៃពីរដាក់តាមបណ្តោយស្មា ជាសញ្ញាអនុញ្ញាតអោយទៅមកបាន ។

មាត្រា ១២ .- ហាមមិនអោយបើកបរយានជំនិះទន្ទឹមគ្នា ។

មាត្រា ១៣ .- ហាមមិនអោយគ្រឿងយន្តកង់ច្រវាក់គ្រប់ប្រភេទបើកបរនៅលើទ្រូងថ្នល់ លើកលែងតែក្នុងករណីមានការអនុញ្ញាតពិសេស ។ គ្រឿងយន្តទាំងនេះ នៅពេលផ្លាស់ប្តូរកន្លែង ត្រូវដាក់លើរថយន្តសំរាប់ដឹកឧបករណ៍ និងគ្រឿងចក្រធុនធ្ងន់ ។

មាត្រា ១៤ .- ហាមមិនអោយរថយន្តដែលមានទម្ងន់សរុបលើសពី ២០ តោនធ្វើចរាចរណ៍លើផ្លូវថ្នល់សាធារណៈ និង ស្ពាន ។ បើមានទម្ងន់លើសពីការកំណត់នេះត្រូវសុំការអនុញ្ញាតពីក្រសួងគមនាគមន៍ដឹកជញ្ជូន និង ប្រៃសណីយ៍ ។

មាត្រា ១៥ .- ក្រុមរថយន្តនិមួយៗដែលអនុញ្ញាតអោយបើកបរជាក្បួន មិនត្រូវមានប្រវែងលើសពី ២៥០ ម៉ែត្រ ។ ចន្លោះពីក្រុមមួយទៅក្រុមមួយទៀត ត្រូវមានប្រវែងតិចបំផុត ២០ ម៉ែត្រ ។

មាត្រា ១៦ .- ហាមមិនអោយទោចក្រយានយន្តសណ្តោងរ៉ឺម៉ក ទោចក្រយានសណ្តោងរ៉ឺម៉កត្រីចក្រយាន រទេះអូសដោយសត្វ ធ្វើចរាចរណ៍ជាក្រុម ដែលមានប្រវែងលើសពី ៦០ ម៉ែត្រ ។ ចន្លោះពីក្រុមមួយទៅក្រុមមួយទៀត ត្រូវមានប្រវែងតិចបំផុត ៦០ ម៉ែត្រ ។ ចន្លោះពីយានមួយទៅយានមួយទៀតដែលធ្វើចរាចរនៅក្នុងក្រុមជាមួយគ្នា ត្រូវមានប្រវែងតិចបំផុត ៣ ម៉ែត្រ ។

មាត្រា ១៧ .- នៅក្នុងក្រុង ទីរួមខេត្ត ឬ ទីប្រជុំជន អ្នកប្រើប្រាស់ផ្លូវសាធារណៈ ត្រូវធ្វើចរាចរណ៍តាមផ្លូវកំណត់ដោយគណៈកម្មាធិការប្រជាជនខេត្ត ក្រុង ។

មាត្រា ១៨ .- អ្នកបើកបរយានជំនិះគ្រប់ប្រភេទ ត្រូវជៀសគ្នានៅខាងស្តាំដៃរបស់ខ្លួន ។ ពេលជៀសគ្នានៅផ្លូវចង្អៀត ឬ ផ្លូវអាចមានគ្រោះថ្នាក់ អ្នកបើកបរត្រូវបន្ថយល្បឿន ។ ក្នុងករណីចាំបាច់អ្នកបើកបរយានជំនិះណាចង់ទៅមុន ត្រូវធ្វើសញ្ញាសុំផ្លូវ ដោយលើកដៃដោយភ្លើងចង្កៀង ឬ ដោយស៊ីផ្លេ ហើយត្រូវរង់ចាំយានជំនិះដែលមកពីខាងមុខបញ្ចេញសញ្ញាយល់ព្រមអោយទៅ ឬ ឈប់ទើបអាចធ្វើដំណើរទៅបាន ។ ពេលជៀសគ្នានៅផ្លូវតូច ដែលចូលបានតែយានជំនិះមួយ តែមានកន្លែងសំរាប់ជៀសគ្នា យានជំនិះណាមកដល់កន្លែងនោះមុន ត្រូវឈប់រង់ចាំ ដើម្បីអោយយានជំនិះមួយទៀតជៀសបានស្រួល ។

ពេលជៀសគ្នានៅចំណោត យានជំនិះចុះចំណោតត្រូវឈប់ដើម្បីទុកអោយយានជំនិះឡើងចំណោតទៅមុន ។ យានជំនិះ ២ ជួបគ្នា យានជំនិះណាមើលឃើញនៅលើផ្លូវខាងមុខខ្លួនមានឧបសគ្គត្រូវឈប់ដើម្បីទុកផ្លូវ អោយយានជំនិះមួយទៀតទៅមុន ។ នៅពេលឈប់យានជំនិះជួបគ្នាត្រូវបិទភ្លើងហ្វា ហើយបើកភ្លើងកូតវិញ ។

មាត្រា ១៩ .- អ្នកបើកបរយានជំនិះគ្រប់ប្រភេទ ត្រូវដែងគ្នានៅខាងឆ្វេងដៃរបស់ខ្លួន ។

នៅពេលថ្ងៃ អ្នកបើកបរយានជំនិះណាចង់ដែងគ្នា ត្រូវស៊ីផ្លេ ។

យានជំនិះដែលបរខាងមុខ បើស្តាប់ឮ ឬ មើលឃើញសញ្ញាសុំជែង ហើយបើ ពិនិត្យឃើញថា នៅខាងមុខគ្មានឧបសគ្គនិងគ្មានគ្រោះថ្នាក់ទេ ត្រូវយល់ព្រមអោយជែង ដោយបន្ថយល្បឿន និងអែបទៅខាងស្តាំដៃ ហើយបញ្ចេញសញ្ញាអោយយានជំនិះខាងក្រោយបានដឹងឮ ឬ ឃើញផង ។ នៅពេលយានជំនិះខាងក្រោយកំពុងជែងយានជំនិះខាងមុខ ត្រូវនៅអែបខាងស្តាំដៃជានិច្ច ហើយមិនត្រូវបង្កើនល្បឿនឡើយ ។

យានជំនិះខាងក្រោយអាចជែងបាននៅពេលមើលឃើញសញ្ញាយល់ព្រមអោយជែងនៃយានជំនិះខាងមុខ តែត្រូវអោយសញ្ញាជែង ហើយក្តាប់អោយបានច្បាស់នូវសភាពផ្លូវខាងមុខ ។ ពេលជែងរួច ហើយយានជំនិះត្រូវអែបខាងស្តាំដៃវិញ ដោយមិនបង្កអោយមានគ្រោះថ្នាក់ដល់យានជំនិះដែលអោយជែង ។

ហាមដាច់មិនអោយជែងគ្នាជា ៣ ជួរ ហើយហាមមិនអោយជែងគ្នានៅផ្លូវបត់ ផ្លូវបំបែក ផ្លូវខ្ពស់ទាប ផ្លូវចង្អៀត កំណាត់ផ្លូវជិតស្ពាន លើស្ពាន ឬ កន្លែងមានសញ្ញាផ្លូវដែកឆ្លងកាត់ ឬ ពេលចុះចំណោត ពេលភ្លៀង ពេលចុះអ័ព្ទ ពេលចុះផ្លូវដីហុយដែលមិនអាចមើលផ្លូវឃើញច្បាស់ ។

មាត្រា ២០ .- អ្នកបើកបរយានជំនិះគ្រប់ប្រភេទត្រូវបន្ថយល្បឿននៅផ្លូវបំបែក ផ្លូវតូច ផ្លូវចង្អៀត ផ្លូវដីហុយ ផ្លូវមានមនុស្សច្រើន ផ្លូវដាក់សញ្ញាបន្ថយល្បឿន ពេលឆ្លងកាត់ស្ពាន ពេលចុះចំណោត ពេលមានភ្លៀង ឬ ចុះអ័ព្ទ ពេលព្រលប់ ពេលព្រលឹម ។

មាត្រា ២១ .- នៅលើផ្លូវក្នុងក្រុង ទីរួមខេត្ត ឬ ទីប្រជុំជន រថយន្តធុនស្រាលមិនត្រូវមានល្បឿនលើសពី ៤០ គ.ម ក្នុងមួយម៉ោង រថយន្តធុនធ្ងន់ ត្រីចក្រយានយន្ត និង ទោចក្រយានយន្តមិនត្រូវមានល្បឿនលើសពី ៣០ គ.ម ក្នុងមួយម៉ោង និង ទោចក្រយានយន្តសណ្តោងរ៉ឺម៉ក មិនត្រូវមានល្បឿនលើសពី ២៥ គ.ម ក្នុង ១ ម៉ោង លើកលែងតែនៅលើផ្លូវមួយចំនួនដែលមានផ្លាកសញ្ញាកំណត់ល្បឿនផ្សេងៗ ពីនេះដោយក្រសួងគមនាគមន៍ ដឹកជញ្ជូន និង ប្រៃសណីយ៍ ។

ក្នុងពេលបំពេញបេសកកម្ម រថយន្តលត់អគ្គីភ័យ រថយន្តសង្គ្រោះអ្នកជំងឺ និង រថយន្តនគរបាល អាចមានល្បឿនលើសពីការកំណត់ខាងលើបាន ប៉ុន្តែត្រូវប្រើសញ្ញាសុំផ្លូវ ភ្លើង ឬ ស៊ីរ៉ែន " ហើយត្រូវធានាសណ្តាប់ធ្នាប់ចរាចរ ។

នៅលើផ្លូវផុតទីប្រជុំជន យានជំនិះគ្រប់ប្រភេទត្រូវមានល្បឿនស្របតាមផ្លាកសញ្ញាកំណត់ល្បឿន របស់ក្រសួងគមនាគមន៍ដឹកជញ្ជូន និង ប្រៃសណីយ៍ ប៉ុន្តែរថយន្តធុនស្រាល មិនត្រូវមានល្បឿន លើសពី ៩០ គ.ម ក្នុង ១ ម៉ោង រថយន្តធុនធ្ងន់មិនត្រូវមានល្បឿនលើសពី ៧១ គ.ម ក្នុង ១ ម៉ោង ។

មាត្រា ២២ .- នៅលើផ្លូវដែលមានសញ្ញាកំណត់ អ្នកបើកបរលើផ្លូវធំ មានសិទ្ធិជាអាទិភាពលើអ្នកបើកបរលើផ្លូវតូច ។

មាត្រា ២៣ .- រថយន្តលត់អគ្គីភ័យ រថយន្តសង្គ្រោះអ្នកជំងឺ ក្បួនរថយន្តដែលមានរថយន្ត ឬ ទោចក្រយានយន្តនគរបាលនាំមុខ រថយន្តនគរបាល ឬ រថយន្តតម្រួតយោធា ដែលមានបន្លឺសំឡេងស៊ីរ៉ែន មានសិទ្ធិជាអាទិភាព ។ បើសិនជារថយន្តមានអាទិភាពដូចបានរៀបរាប់ខាងលើធ្វើចរាចរណ៍ស្របពេលជាមួយគ្នានោះ អាទិភាពត្រូវផ្តល់អោយរថយន្តអគ្គីភ័យ រួចមករថយន្តសង្គ្រោះអ្នកជំងឺ ។

ក្នុងករណីចាំបាច់ជាបន្ទាន់ ដោយមកពីមានមហន្តរាយធ្ងន់ធ្ងរ ព្រោះថ្នាក់ដល់អាយុជីវិតមនុស្ស ឬ មានចលាចលក្នុងសង្គម រថយន្តលត់អគ្គីភ័យ រថយន្តសង្គ្រោះអ្នកជម្ងឺ រថយន្តនគរបាល រថយន្តត្រួតយោធា អាចបើកបរបញ្ច្រាសទិស ដែលមានសញ្ញាហាមឃាត់បាន ប៉ុន្តែត្រូវប្រើសញ្ញាសុំផ្លូវ ។

ក្នុងខណៈខាងលើទាំងនេះ អ្នកធ្វើចរាចរទាំងឡាយ ត្រូវឈប់នៅខាងស្តាំដៃរបស់ខ្លួន ហើយនឹងធ្វើចរាចរវិញបាន លុះត្រាតែរថយន្តខាងលើបានចេញផុតពីកន្លែងដែលខ្លួនឈប់ ។

មាត្រា ២៤ .- ពេលជិតមកដល់ផ្លូវបំបែក ឬ រង្វង់មូល អ្នកបើកបរត្រូវបន្ថយល្បឿន និងត្រូវបញ្ចេញសញ្ញា : ស៊ីផ្លេពេលថ្ងៃ ភ្លើងសញ្ញាពេលយប់ ។

- នៅផ្លូវបំបែកដែលមានសិទ្ធិស្មើគ្នា យានជំនិះដែលគ្មានយានជំនិះនៅខាងស្តាំរបស់ខ្លួន មានសិទ្ធិជាអាទិភាព ។
- នៅរង្វង់មូល យានជំនិះស្ថិតនៅក្នុងរង្វង់មូលមានសិទ្ធិជាអាទិភាព ។

មាត្រា ២៥ .- នៅពេលមកដល់ជិតស្ពានដំណាលគ្នា សំរាប់រថយន្តតែមួយ រថយន្តផ្ទុកស្រាល មានអាទិភាពលើរថយន្តផ្ទុកធ្ងន់ ។

ក្នុងករណីដែលរថយន្តមួយបានចូលស្ពានរួចទៅហើយ រថយន្តនោះមានសិទ្ធិជាអាទិភាព។ បើស្ពានមានក្រាលក្តារឈ្លាក់តាមបណ្តោយសំរាប់ទ្រកង់ យានជំនិះត្រូវបរលើក្តារនោះ ។ នៅលើស្ពានដែលមានប្រវែងតិចជាង ២០ ម៉ែត្រ យានយន្តដែលមានទម្ងន់ធ្ងន់ ឬ រថយន្តផ្ទុកទំនិញធ្ងន់ ត្រូវឆ្លងស្ពានម្តងមួយៗ ទោះជាមានសណ្តោងគ្នាក៏ដោយ ។

នៅលើស្ពានដែលមានផ្លូវរថភ្លើង អ្នកធ្វើចរាចរគ្រប់ប្រភេទ ត្រូវអនុវត្តតាមការណែនាំ ឬ សញ្ញាទង់របស់ភ្នាក់ងារមានសមត្ថកិច្ចប្រចាំការនៅទីនោះ តាមភ្លើងសញ្ញា ឬ ផ្លាកសញ្ញា ប្រសិនបើមាន ។ ក្នុងករណី គ្មានភ្នាក់ងារមានសមត្ថកិច្ចនៅប្រចាំការ ហើយមានរថភ្លើងមកដល់ រថភ្លើងត្រូវមានសិទ្ធិជាអាទិភាព ។ នៅលើស្ពានហាមមិនអោយយានយន្តមានទម្ងន់ធ្ងន់ធ្វើចរាចរណ៍ជាខ្សែ ឬ ជាក្បួន ។

មាត្រា ២៦ .- នៅកំពង់ចំលងយានជំនិះមកដល់មុន មានសិទ្ធិឆ្លងមុន លើកលែងតែករណីយានយន្តដែលមានចែងក្នុងមាត្រា ២៣ រថយន្តរបស់ថ្នាក់ដឹកនាំ រថយន្តទូត រថយន្តនាំសារ រថយន្តក្រសួងគមនាគមន៍ដឹកជញ្ជូន និង ប្រៃសណីយ៍ ដែលមានភារកិច្ចជួសជុលស្ពានថ្នល់ជាបន្ទាន់ ។ ក្រៅពីរថយន្តមានអាទិភាពខាងលើនេះ រថយន្តដែលចាត់ទុកថាមានអាទិភាពជាបន្តបន្ទាប់គឺ :

១- រថយន្តដឹកសុទ្ធតែសាច់ស្រស់ បន្លែស្រស់ ទំនិញឆាប់រលួយ ស្អុយ ឬ សត្វរស់ ។

២- រថយន្តទេសចរណ៍ដែលកំពុងដឹកភ្ញៀវ ធ្វើទស្សនកិច្ច ។

៣- រថយន្តអាជីវកម្មដឹកអ្នកដំណើរ ។

នៅពេលឆ្លងកំពង់ចម្លង អ្នកដំណើរទាំងអស់ត្រូវចុះពីយានជំនិះ ។ អ្នកបើកបរយានជំនិះគ្រប់ប្រភេទ ត្រូវគោរពបទបញ្ជារបស់កំពង់ចម្លង តាមការណែនាំរបស់បុគ្គលិកប្រចាំការនៅទីនោះ ។

មាត្រា ២៧ . ពេលជិតមកដល់ផ្លូវរថភ្លើង អ្នកបើកបរយានជំនិះគ្រប់ប្រភេទត្រូវបន្ថយល្បឿន ហើយ ឈប់នៅនឹងកន្លែង ចម្ងាយប្រវែងពីរម៉ែត្រពីរបាំងផ្លូវរថភ្លើង តាមការបញ្ជាពីភ្នាក់ងារទទួលខុសត្រូវនៅទីនោះ ។

ក្នុងករណីគ្មានរបាំង គ្មានភ្នាក់ងារទទួលខុសត្រូវ ពេលឃើញរថភ្លើងជិតមកដល់ អ្នកធ្វើចរាចរណ៍គ្រប់ប្រភេទត្រូវឈប់ចម្ងាយយ៉ាងតិច ៥ ម៉ែត្រ ពីផ្លូវរថភ្លើង ។

ហាមមិនអោយធ្វើចរាចរលើផ្លូវរថភ្លើង ។

មាត្រា ២៨ .. ការចតយានជំនិះ ត្រូវហាមឃាត់ក្នុងករណីដូចខាងក្រោម :

ក- នៅកន្លែងដែលមានផ្លាកសញ្ញា ហាមមិនអោយចត ។
ខ- នៅកន្លែងដែលមានផ្លាកសញ្ញា ហាមមិនអោយឈប់ ។
គ- នៅកន្លែងដែលបំរុងទុកសំរាប់យានជំនិះប្រភេទផ្សេងទៀត ។
ឃ- នៅចម្ងាយតិចជាង ១២ ម៉ែត្រពីផ្លូវបំបែក ឬ ផ្លូវបត់ និង ចម្ងាយកង់ឡានលើសពី ២០ ស.ម ពីចញ្ចើមថ្នល់ ឬ ជាយថ្នល់ ។
ង- កន្លែងដែលមានរថយន្តចតនៅម្ខាងថ្នល់ហើយ លើកលែងតែថ្នល់នោះអាចចតបានទាំង ២ ខាង ។
ច- នៅច្រកចេញ-ចូល លើកលែងតែរថយន្តរបស់ម្ចាស់អចលនវត្ថុនោះ ។
ឆ- នៅមុខច្រកចេញ-ចូល សាលទស្សនីយភាព សាលប្រជុំ ។
ជ- នៅលើគំនូសអង្កត់កាត់ទទឹងថ្នល់ ឬ ផ្លូវព្រោះដែកគោលសំរាប់ថ្មើរជើង ។
ឈ- នៅមុខមន្ទីរអន្តរាគមន៍អគ្គិភ័យ ឬ មន្ទីរនគរបាល នៅ កន្លែងបូមទឹក សំរាប់អគ្គិភ័យ ។
ញ- នៅលើស្ពាន លើចំណោត ឬ នៅវង្វង់មូល ។
ដ- នៅលើផ្លូវរថភ្លើង ដែលឆ្លងកាត់ថ្នល់ ។

មាត្រា ២៩ .. អ្នកបើកបររថយន្តគ្រប់ប្រភេទ ត្រាក់ទ័រ ត្រីចក្រយានយន្ត និង ទោចក្រយានយន្ត ដែលមានចំណុះស៊ីឡាំង ចាប់ពី ១០០ សង់ទីម៉ែត្រគីបឡើងទៅ ត្រូវមានប័ណ្ណបើកបរចេញដោយក្រសួងគមនាគមន៍ដឹកជញ្ជូននិងប្រៃសណីយ៍ ។

នគរបាលជាអ្នកបើកបររថយន្ត ទោចក្រយានយន្ត ឬ ត្រីចក្រយានយន្តដែលជាទ្រព្យសម្បត្តិរបស់រដ្ឋ ត្រូវមានប័ណ្ណបើកបរចេញដោយក្រសួងមហាផ្ទៃ ។

នគរបាលដែលប្រើប្រាស់រថយន្ត ទោចក្រយានយន្ត ឬ ត្រីចក្រយានយន្តជាកម្មសិទ្ធិផ្ទាល់ខ្លួន ត្រូវមានប័ណ្ណបើកបរចេញដោយក្រសួងគមនាគមន៍ដឹកជញ្ជូន និង ប្រៃសណីយ៍ ។

យោធាជាអ្នកបើកបររថយន្ត ទោចក្រយានយន្ត ឬ ត្រីចក្រយានយន្ត ដែលជាទ្រព្យសម្បត្តិរបស់រដ្ឋ ត្រូវមានប័ណ្ណបើកបរចេញដោយក្រសួងការពារប្រទេស ។

យោធាដែលប្រើប្រាស់រថយន្ត ទោចក្រយានយន្ត ឬ ត្រីចក្រយានយន្តដែលជាកម្មសិទ្ធិផ្ទាល់ខ្លួន ត្រូវមានប័ណ្ណបើកបរចេញដោយក្រសួងគមនាគមន៍ដឹកជញ្ជូន និង ប្រៃសណីយ៍ ។

អ្នកសុំបើកបរត្រូវពិនិត្យកាយសម្បទានៅក្រសួង មន្ទីរ ឬ ការិយាល័យសុខាភិបាលជាមុន ។

មាត្រា ៣០ .. ប័ណ្ណបើកបរមាន ០៥ ប្រភេទ

១- ប័ណ្ណបើកបរទោចក្រយានយន្ត អ្នកមានប័ណ្ណនេះអាចបើកបរវេស្បា និង ទោចក្រយានយន្ត " ម៉ូតូ " ដែលមានចំណុះស៊ីឡាំងពី ១០០ សង់ទីម៉ែត្រគីប រហូតដល់ ១២៥ សង់ទីម៉ែត្រគីប ។

អ្នកកាន់ប័ណ្ណនេះ ត្រូវមានអាយុចាប់ពី ១៨ ឆ្នាំ ឡើងទៅ ។

២- ប័ណ្ណបើកបររថយន្តធុនស្រាល ឬ ធុនទេសចរណ៍ និង រថយន្តធុនមធ្យម ដែលមានទម្ងន់សរុបក្រោម ៣.៥០០ គីឡូក្រាម ។ អ្នកកាន់ប័ណ្ណនេះត្រូវមានអាយុពី ១៨ ឆ្នាំឡើងទៅ ។

៣- ប័ណ្ណបើកបររថយន្តធុនធ្ងន់ដឹកអ្នកដំណើរ អ្នកមានប័ណ្ណនេះអាចបើកបររថយន្តដែលមានទម្ងន់សរុបចាប់ពី ៣.៥០០ គីឡូក្រាម និង ត្រូវមានអាយុចាប់ពី ២៦ឆ្នាំឡើងទៅ។

៤- ប័ណ្ណបើកបររថយន្តធុនធ្ងន់ដឹកទំនិញ អ្នកមានប័ណ្ណនេះអាចបើកបររថយន្តដែលមានទម្ងន់សរុបចាប់ពី ៣.៥០០ គីឡូក្រាមឡើងទៅ និងត្រូវមានអាយុចាប់ពី ២២ ឆ្នាំឡើងទៅ ។

៥- ប័ណ្ណបើកបរត្រាក់ទ័រកសិកម្ម អ្នកមានប័ណ្ណនេះអាចបើកបរត្រាក់ទ័រកសិកម្មទាំងឡាយដោយមាន ឬ គ្មានរ៉ឺម៉ក និង ត្រូវមានអាយុចាប់ពី ១៨ ឆ្នាំ ឡើងទៅ ។

អ្នកដែលមានប័ណ្ណបើកបរយានយន្តប្រភេទណា ត្រូវបើកបរយានយន្តប្រភេទនោះ ។ ប៉ុន្តែក្នុងករណីដែលអ្នកបើកបរមានប័ណ្ណបើកបររថយន្តធុនធ្ងន់ដឹកអ្នកដំណើរ អាចបើកបររថយន្តគ្រប់ប្រភេទបាន និងមានប័ណ្ណបើកបររថយន្តធុនធ្ងន់ដឹកទំនិញ អាចបើកបររថយន្តធុនស្រាល ឬ ត្រាក់ទ័រកសិកម្មបាន ។

ចំពោះអ្នកបើកបរយានយន្តុបករណ៍ក៏ត្រូវមានប័ណ្ណបើកបររថយន្តធុនធ្ងន់ និង វិញ្ញាបនប័ត្របញ្ជាក់សមត្ថភាពប្រើប្រាស់យានយន្តុបករណ៍នោះ ដែលចេញដោយសាមីអង្គភាព ។

ជនបរទេសដែលបើកបររថយន្តទៅលើផ្លូវសាធារណៈនៃរដ្ឋកម្ពុជា ត្រូវមានប័ណ្ណបើកបរចេញដោយសាមីប្រទេស ព្រមទាំងមានការអនុញ្ញាតពីក្រសួងគមនាគមន៍ដឹកជញ្ជូន និង ប្រៃសណីយ៍ទៀតផង ក្នុងករណីគ្មានប័ណ្ណបើកបរចេញដោយសាមីប្រទេស ត្រូវធ្វើពាក្យសុំប្រលងប័ណ្ណបើកបរនៅក្រសួងគមនាគមន៍ដឹកជញ្ជូន និង ប្រៃសណីយ៍ ។

មាត្រា ៣១ .- អ្នកបើកបរគ្រប់ប្រភេទ មិនត្រូវផឹកស្រា និង ជាតិស្រវឹងក្នុងពេលបើកបរ ។

## ជំពូកទី ៤

## លក្ខណៈបច្ចេកទេស នៃ យានជំនិះ

មាត្រា ៣២ .- យានជំនិះគ្រប់ប្រភេទត្រូវមានប្រព័ន្ធហ្វ្រាំង និង ប្រដាប់បន្លឺសំឡេង កញ្ចក់មើលក្រោយនិងសំភារៈសុវត្ថិភាព លើកលែងតែរទេះអូស រុញដោយមនុស្ស ឬ អូសដោយសត្វ ។

មាត្រា ៣៣ .- យានយន្តគ្រប់ប្រភេទ ត្រូវមានផ្លាកលេខច្បាស់ល្អ មានភ្លើងបំភ្លឺ និងមានភ្លើងសញ្ញាទាំងមុខ ទាំងក្រោយ ។

មាត្រា ៣៤ .- រថយន្តសណ្តោងរ៉ឺម៉ក ពេលថ្ងៃត្រូវដាក់សញ្ញារាងត្រីកោណ ពណ៌លឿងនៅលើកាប៊ីន ។ ពេលយប់រថយន្តសណ្តោងរ៉ឺម៉កត្រូវដាក់កញ្ចក់កាតាហ្វូតរាងមូល ពណ៌ក្រហម ទាំងនៅខាងមុខរថយន្ត និង ខាងក្រោយរ៉ឺម៉ក ។

ក្នុងករណីរថយន្តសណ្តោងរ៉ឺម៉កជាច្រើនបន្តគ្នា រ៉ឺម៉កចុងក្រោយត្រូវដាក់លេខរ៉ឺម៉ក និង លេខរថយន្ត ។ ពេលថ្ងៃ និង ពេលយប់ត្រូវដាក់សញ្ញាដូចមានចែងខាងលើ ទាំងនៅខាងមុខរថយន្ត និងខាងក្រោយរ៉ឺម៉ក ។ រថយន្ត និងរ៉ឺម៉ក ត្រូវបន្តភ្ជាប់គ្នាអោយបានមាំមួនល្អ ។

មាត្រា ៣៥ យានជំនិះគ្រប់ប្រភេទត្រូវមានទទឹងអតិបរិមា ២ម.៥០ និងកំពស់អតិបរិមា ៣ម៥០ ។ ចំពោះរថយន្ត ហាមមិនអោយរៀបទំនិញចេញក្រៅពីគែមចំហៀង និង មានកំពស់ពី ៣ម៥០ គិតពីផ្ទៃដីឡើងទៅ ។

ក្នុងករណីសំភារៈ ឬ គ្រឿងចក្រធំៗ យានជំនិះទាំងនោះអាចមានទទឹងលើសពី ២ម.៥០ ។ ទំនិញដែលផ្ទុកលើរថយន្តដឹកជញ្ជូនធុនធំ លើរថយន្តសណ្តោងរ៉ឺម៉ក និងត្រូវលូតចេញទៅខាងមុខ និងទៅខាងក្រោយលើសពី ៣ ម៉ែត្រ ។

ចំពោះរទេះអូសដោយសត្វ ត្រូវមានបន្ទាដែកពាក់ ឬ កៅស៊ូព័ទ្ធកង់ ប្រវែងតិចបំផុត ៥ ស.ម ។ ក្នុងករណីមានពាក់កៅស៊ូក្បាលដែកគោល វាយភ្ជាប់ទៅនឹងកង់ ត្រូវមានបន្ទាត់ផ្ចិតតិចបំផុត ១ ស.ម ហើយលេចផុតពីផ្ទៃកៅស៊ូ ខ្ពស់បំផុត ០,៥០ ស.ម ។ រទេះដែលផ្ទុកទំនិញហើយ មិនត្រូវមានបណ្តោយលើសពី ១០ ម និង កំពស់លើសពី ២ ម គិតពីផ្ទៃដីឡើងទៅ

ចំពោះស៊ីក្លូ មិនអនុញ្ញាតអោយរៀបទំនិញពាំងមុខអ្នកធាក់ស៊ីក្លូឡើយ ។

ចំពោះរទេះសេះ មិនអនុញ្ញាតអោយផ្ទុកមានទម្ងន់លើសពី ៥០០ គក្រឡើយ ។

ចំពោះរ៉ឺម៉កម៉ូតូ មិនអនុញ្ញាតអោយផ្ទុកមនុស្សលើសពី ៦ នាក់ ឬបើមានផ្ទុកទំនិញផង ទម្ងន់សរុបមិនត្រូវលើសពី ៥០០ គក្រ ។

មាត្រា ៣៦ .- បណ្តោយនៃរថយន្តគ្រប់ប្រភេទដោយគិតទាំងទំនិញ ឧបករណ៍ ឬ សំភារៈដែលផ្ទុកផង ត្រូវកំណត់ដូចតទៅ ។

ក- រថយន្តមានភ្លៅកង់ ២ ឬ រថយន្តកង់ ៦ ត្រូវមានបណ្តោយអតិបរិមា ១០ ម ។

ខ- រថយន្តមានភ្លៅកង់ ៣ ឬ រថយន្តកង់ ១០ ត្រូវមានបណ្តោយអតិបរិមា ១១ ម ។

គ- រថយន្តសំរាប់ដឹកឧបករណ៍ និង គ្រឿងចក្រគ្រប់ធុនធំ ត្រូវមានបណ្តោយអតិបរិមា ១៥ ម ។

ឃ- រថយន្តសណ្តោងរ៉ឺម៉ក ត្រូវមានបណ្តោយអតិបរិមា ១៥ ម ។

មាត្រា ៣៧ .- ទម្ងន់សង្កត់លើដីដោយរថយន្តមួយ មិនត្រូវលើសពី ១៥០ គក្រក្នុង ១ ស.ម នៃប្រវែងបន្ទាសំបកកង់ឡើយ ។ ប្រវែងបន្ទានេះ ត្រូវវាស់តែបន្ទាសំបកកង់ថ្មីដែលជិតនឹងដីនឹងមិនស្រុតក្នុងពេលធ្វើចលនាធម្មតា ។

កង់របស់រថយន្តក៏ដូចជាកង់របស់រ៉ឺម៉កដែរ ត្រូវមានសំបកកៅស៊ូ មិនរលប់ក្រឡាគ្មានប្រេះ ។

មាត្រា ៣៨ .- ការត្រួតពិនិត្យលក្ខណៈបច្ចេកទេសចំពោះយានយន្តប្រើប្រាស់ ធ្វើអាជីវកម្មជាសមត្ថកិច្ចរបស់ក្រសួងគមនាគមន៍ដឹកជញ្ជូន និង ប្រៃសណីយ៍ ។

<u>ជំពូកទី ៥</u>

<u>អំពីសិទ្ធិរបស់អង្គការមានសមត្ថកិច្ចដោះស្រាយបទល្មើស</u>

<u>និងបទបញ្ជាចរាចរណ៍</u>

មាត្រា ៣៩ .- នៅពេលមានគ្រោះថ្នាក់ចរាចរណ៍ តម្រួតចរាចរណ៍ មានសិទ្ធិដូចតទៅ

- ចុះធ្វើការពិនិត្យកត់ត្រា ស៊ើបអង្កេតកន្លែងកើតហេតុ
- សម្រួលចរាចរណ៍អោយមានសណ្ដាប់ធ្នាប់ និង សន្តិសុខ
- ពិនិត្យប័ណ្ណបើកបរអត្តសញ្ញាណប័ណ្ណ ប័ណ្ណសំគាល់យានជំនិះ និង សៀវភៅត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានជំនិះពីអ្នកបើកបរយានជំនិះ ។
- ឃាត់ខ្លួនជាបណ្ដោះអាសន្នជនប្រព្រឹត្តបទល្មើស ដើម្បីពិនិត្យ និង ធ្វើកំណត់ហេតុគ្រោះថ្នាក់ចរាចរណ៍ ។

មាត្រា ៤០.- ជនណាបានឃើញគ្រោះថ្នាក់ចរាចរណ៍ត្រូវរិះរកគ្រប់មធ្យោបាយ ដើម្បីជួយសង្គ្រោះជនរងគ្រោះ ដោយបញ្ជូនទៅមន្ទីរពេទ្យដែលនៅជិតបំផុត និង ផ្ដល់ដំណឹងជាបន្ទាន់ទៅនគរបាលចរាចរណ៍ ។

នៅពេលបានទទួលដំណឹងពីគ្រោះថ្នាក់ចរាចរណ៍ នគរបាលចរាចរណ៍ត្រូវចុះទៅពិនិត្យជាបន្ទាន់ ។

មាត្រា ៤១.- ចំពោះគ្រោះថ្នាក់ចរាចរណ៍ណាដែលមានភាគីម្ខាងជាភ្នាក់ងារទូត ឬ បេសកកម្មទូត តម្រួតចរាចរណ៍ត្រូវធ្វើកំណត់ហេតុ និង ធ្វើរបាយការណ៍មួយស្ដីពីគ្រោះថ្នាក់ចរាចរណ៍នេះ ផ្ញើទៅក្រសួងការបរទេស ដើម្បីប្រជាបជាពត៌មាន និង ចាត់តំណាងអោយចូលរួមសហការជាមួយតម្រួតចរាចរណ៍ក្នុងការពិនិត្យ និង ដោះស្រាយ ។

មាត្រា ៤២.- ក្នុងករណីគ្រោះថ្នាក់ចរាចរណ៍ ទោះបីជនល្មើសជាយោធិនក៏ដោយ ការស៊ើបអង្កេតដោះស្រាយ ជាសមត្ថកិច្ចរបស់ស្ថាប័ននគរបាល ។ ក្នុងករណីធ្ងន់ធ្ងរ ស្ថាប័ននគរបាលមានសមត្ថកិច្ចត្រូវបញ្ជូនសំណុំរឿងសព្វគ្រប់ទៅតុលាការប្រជាជនខេត្ត ក្រុង ដើម្បីសំរេច ។

មាត្រា ៤៣.- សមត្ថកិច្ចដោះស្រាយបទល្មើសនឹងបទបញ្ជាចរាចរណ៍ត្រូវកំណត់ដូចតទៅ ៖-

- ភ្នាក់ងារតម្រួតចរាចរណ៍ខេត្ត ក្រុង មានសិទ្ធិណែនាំ ព្រមាន និង ពិន័យជាប្រាក់ពី ៥០០ រៀល ដល់ ១.៥០០ រៀល ។
- ការិយាល័យតម្រួតចរាចរណ៍ខេត្ត ក្រុង មានសិទ្ធិពិន័យជាប្រាក់ពី ១.៥០១ រៀល ដល់ ១២.០០០ រៀល និង ធ្វើការសំរុះសំរួលពីសំណងនៃការខូចខាតសំភារៈ ។ បើការសំរុះសំរួលនេះមិនបានសំរេច ត្រូវបញ្ជូនសំណុំរឿងទៅមន្ទីរនគរបាលខេត្ត ក្រុង ពិនិត្យ សំរេច ។
- មន្ទីរនគរបាលខេត្ត ក្រុង មានសិទ្ធិពិន័យជាប្រាក់ពី ១២.០០១ រៀល ដល់ ៤០.០០០រៀល ដកហូតប័ណ្ណបើកបរ តាមការកំណត់របស់ក្រសួងមហាផ្ទៃ និង ធ្វើការសំរុះសំរួលអំពីសំណងនៃការខូចខាតសំភារៈ ។ បើការសំរុះសំរួលមិនបានសំរេច ត្រូវបញ្ជូនសំណុំរឿងទៅតុលាការប្រជាជនខេត្ត ក្រុង ។

ប្រាក់ពិន័យត្រូវបង់ចូលថវិការដ្ឋក្រោយពីកាត់ ៤០ ភាគរយ សំរាប់ផ្ដល់ជារង្វាន់ដល់ភ្នាក់ងារតម្រួតចរាចរណ៍ ឬ អង្គភាពតម្រួតចរាចរណ៍ ។

មាត្រា ៤៤.- សមត្ថកិច្ចដោះស្រាយបណ្តឹងតវ៉ាអំពីពិន័យ ត្រូវកំណត់ដូចតទៅ :-

- ការតវ៉ាលើសេចក្តីសំរេចអំពីពិន័យរបស់ភ្នាក់ងារតម្រួតចរាចរណ៍ ត្រូវការិយាល័យតម្រួតចរាចរណ៍ ខេត្ត ក្រុងសំរេច ។
- ការតវ៉ាលើសេចក្តីសំរេចអំពីពិន័យ និង សេចក្តីសំរេចផ្សេងៗ ទៀតរបស់ការិយាល័យតម្រួតចរាចរណ៍ខេត្ត ក្រុង ត្រូវមន្ទីរនគរបាលខេត្ត ក្រុងសំរេច ។
- ការតវ៉ាលើសេចក្តីសំរេចអំពីពិន័យ និង សេចក្តីសំរេចផ្សេងៗទៀតរបស់មន្ទីរនគរបាលខេត្ត ក្រុង ត្រូវគណៈកម្មាធិការប្រជាជនខេត្ត ក្រុងសំរេច ។

មាត្រា ៤៥.- ក្នុងករណីជនប្រព្រឹត្តល្មើសនឹងបទបញ្ជាចរាចរណ៍មិនព្រមបង់ប្រាក់ពិន័យ ត្រូវបញ្ជូនសំណុំរឿងទៅតុលាការប្រជាជនខេត្ត ក្រុងពិនិត្យសំរេច ។

## ជំពូកទី ៦

## ទោសបញ្ញត្តិស្តីអំពីបទល្មើសនឹងបទបញ្ជាចរាចរណ៍

មាត្រា ៤៦.- អ្នកបើកបរណាប្រព្រឹត្តល្មើសនឹងបទបញ្ជាចរាចរណ៍ ក្នុងពេលបំពេញភារកិច្ច បង្កអោយមានគ្រោះថ្នាក់ ត្រូវទទួលខុសត្រូវខាងបទព្រហ្មទណ្ឌទៅតាមកំរិតនៃគ្រោះថ្នាក់ ។ រីឯអង្គភាពសាមី ឬ អ្នកបញ្ជា ត្រូវទទួលខុសត្រូវខាងបទរដ្ឋប្បវេណី ។

ក្រៅពីពេលបំពេញភារកិច្ច ឬ គ្មានអ្នកបញ្ជា អ្នកបើកបរណាប្រព្រឹត្តល្មើសនឹងបទបញ្ជាចរាចរណ៍ បណ្តាលអោយមានគ្រោះថ្នាក់ ត្រូវទទួលទោសទាំងបទព្រហ្មទណ្ឌផង និង បទរដ្ឋប្បវេណីផង ។

មាត្រា ៤៧.- ត្រូវទទួលការអប់រំណែនាំ ឬ ព្រមានចំពោះជនដែលបានប្រព្រឹត្តល្មើសនឹងមាត្រា ៥ ៧.៩.១១ ចំណុច ១ មាត្រា ១២.១៥.១៦.២៣.២៦.២៧ នៃច្បាប់នេះ ។

មាត្រា ៤៨.- ត្រូវពិន័យជាប្រាក់ពី ៥០០ រៀល ដល់ ១.០០០រៀល ចំពោះជនដែលបានប្រព្រឹត្តល្មើសនឹងមាត្រា ១៧.១៨.១៩.២០.២១.២២.២៤.២៥.២៨.៣៣.៣៥ នៃច្បាប់នេះ ។

មាត្រា ៤៩.- ត្រូវពិន័យជាប្រាក់ពី ១.០០១រៀលដល់ ១.៥០០រៀល ចំពោះជនដែលបានប្រព្រឹត្តល្មើសនឹងមាត្រា ១១ ចំណុច ២ និង ៣មាត្រា ១៣.២៩.៣០.៣២.៣៤.៣៦.៣៧ នៃច្បាប់នេះ ។

មាត្រា ៣២ នៃច្បាប់នេះ មិនត្រូវអនុវត្តទៅលើជនប្រើប្រាស់ទោចក្រយានទេឡើយ។ ចំពោះអ្នកប្រើប្រាស់ទោចក្រយានយន្តដែលប្រព្រឹត្តល្មើសនឹងមាត្រា ៣២ នេះ ត្រូវពិន័យជាប្រាក់ពី ១០០ រៀល ដល់ ៥០០រៀល ។

មាត្រា ៥០.- ត្រូវដកហូតប័ណ្ណបើកបរជាបណ្តោះអាសន្នក្នុងរយៈពេលមួយខែ ដល់ ៦ខែ ចំពោះជនណាដែលបានផឹកស្រា ឬ ជាតិស្រវឹង ក្នុងពេលដែលខ្លួនបើកបរ និង ពិន័យជាប្រាក់ពី ១.៥០១រៀល ដល់ ១២.០០០រៀល ។ ក្នុងករណី ពុំរាងចាលត្រូវដកហូតប័ណ្ណបើកបរនេះជាស្ថាពរ និង ពិន័យជាប្រាក់ទ្វេរមួយជាបី ។

មាត្រា ៥១.- ជនណាលែងសត្វដែលខ្លួនបានចិញ្ចឹមអោយដើរកស៊ី ឬ ជនជាអាណាព្យាបាលបណ្តោយអោយក្មេងមានអាយុតិចជាង ៦ឆ្នាំ ដើររទេះរហូតលើផ្លូវសាធារណៈ បណ្តាលអោយមានគ្រោះថ្នាក់ចរាចរណ៍ត្រូវទទួលខុសត្រូវខាងរដ្ឋប្បវេណី ។

មាត្រា ៥២.- ជនណាដែលដាក់វត្ថុ ឬ សំភារៈបង្កអោយស្ទះចរាចរណ៍បណ្តាលអោយខូចខាតទ្រព្យសម្បត្តិរដ្ឋ ឬ ទ្រព្យសម្បត្តិប្រជាជនត្រូវទទួលខុសត្រូវខាងរដ្ឋប្បវេណី ។

មាត្រា ៥៣.- ជនណាប្រព្រឹត្តល្មើសនឹងមាត្រា ១៤ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ក្នុងទម្ងន់លើសមួយតោន ៥.០០០រៀល ។ ក្នុងករណីពុំរាងចាលត្រូវផ្តន្ទាទោសពិន័យជាប្រាក់នេះទ្វេរមួយជាបី ។

មាត្រា ៥៤.- អនីតិជនណាប្រព្រឹត្តល្មើសនឹងមាត្រា ១០ នៃច្បាប់នេះ ត្រូវអប់រំព្រមាន ។

ក្នុងករណីពុំរាងចាលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី១០.០០០រៀល ទៅ ២០.០០០រៀល។

មាត្រា ៥៥.- ជនណាប្រើប្រាស់រថយន្តដែលមិនទាន់បានសេចក្តីអនុញ្ញាតអោយធ្វើចរាចរ និង លិខិតទាំងឡាយតាមបទបញ្ជា ជនណាក្លែងផ្លាកលេខយាន ឬ ប្រើផ្លាកលេខយានក្លែងក្លាយ ក្លែងប័ណ្ណបើកបរ ប័ណ្ណសំគាល់យានយន្ត ឬ ប្រើប័ណ្ណបើកបរ ប័ណ្ណសំគាល់យានយន្តក្លែងក្លាយ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពីមួយឆ្នាំ ដល់បីឆ្នាំ ។

មាត្រា ៥៦.- ជនណាបើកបរធ្វើអោយអ្នកដទៃមានរបួសរហូតទៅដល់ការអាក់ខានប្រកបការងារមួយរយៈដោយខ្វះការប្រុងប្រយ័ត្ន ជននោះត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពីមួយខែ ដល់មួយឆ្នាំ ក្នុងករណីគ្រោះថ្នាក់ចរាចរណ៍នោះបណ្តាលមកពីការមិនគោរព តាមបទបញ្ជាចរាចរណ៍ទាំងឡាយវិញ ជននោះត្រូវមានទោសដូចខាងលើ ជាអតិបរិមា ។

មាត្រា ៥៧.- ជនណាបើកបរធ្វើអោយអ្នកដទៃមានគ្រោះថ្នាក់ដល់ពិការៈ ស្លាប់ រាងកាយត្រង់ណាមួយអោយមានកាយវិកលកម្ម អោយបាត់បង់អវៈយវៈ ឬ វិញ្ញាណណាមួយ ជននោះត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពីមួយឆ្នាំ ដល់បីឆ្នាំ ។

ក្នុងករណីគ្រោះថ្នាក់ចរាចរណ៍នោះបណ្តាលមកពីការមិនគោរព តាមបទបញ្ជាចរាចរណ៍ទាំងនោះវិញ ជននោះត្រូវមានទោសដូចខាងលើនេះជាអតិបរិមា និង ត្រូវដកហូតប័ណ្ណបើកបរជាបណ្តោះអាសន្នក្នុងរយៈពេលមិនអោយលើសពីបីឆ្នាំ ។

មាត្រា ៥៨.- ជនណាដែលត្រូវបានដកហូតប័ណ្ណបើកបរយានយន្តរួចហើយ នៅតែបន្តបើកបរទៀត ឬ ប្តឹងក្លែងដើម្បីសុំប័ណ្ណបើកបរមួយផ្សេងៗទៀត ជននោះត្រូវផ្តន្ទាទោសពន្ធនាគារពីមួយឆ្នាំដល់បីឆ្នាំ ។

មាត្រា ៥៩.- ជនណាបើកបរល្មើសនឹងបទបញ្ជាចរាចរណ៍ បណ្តាលអោយមានគ្រោះថ្នាក់ដល់សុខភាពអាយុជីវិតអ្នកដទៃ ហើយគេចខ្លួន ជននោះត្រូវផ្តន្ទាទោសពន្ធនាគារបន្ថែមទៀតពីមួយខែដល់មួយឆ្នាំ ។

មាត្រា ៦០.- ជនណាបើកបរបណ្តាលអោយមានគ្រោះថ្នាក់ដល់ស្លាប់ អ្នកដទៃដោយចេតនា ជននោះត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ឆ្នាំ ដល់ ៥ឆ្នាំ ។ ក្នុងករណីគ្រោះថ្នាក់ចរាចរណ៍នោះបណ្តាលមកពីមិនគោរពតាមបទបញ្ជាចរាចរណ៍ទាំងឡាយវិញ ជននោះត្រូវផ្តន្ទាទោសដាក់ពន្ធនាគារខាងលើនេះជាអតិបរិមា ។

មាត្រា ៦១. - ទណ្ឌកម្មដែលមានចែងក្នុងច្បាប់នេះទាំងប៉ុន្មាន ត្រូវតែយកទៅផ្តន្ទាទោសជាដរាប ។ ក៏ប៉ុន្តែទណ្ឌកម្មទាំងនោះ មិនមែនជាឧបសគ្គដល់ការដាក់ទណ្ឌកម្មអោយសងសំណង និង បង់ជម្ងឺចិត្ត ដែលជនរងគ្រោះបានតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ប្តឹងសុំទាមទារអោយតុលាការទទួលស្គាល់ និង ជួលជុលព្យសនកម្មដែលខ្លួនទទួលរងគ្រោះនោះ បន្ថែមពីលើទោសពន្ធនាគារ ឬទោសពិន័យជាប្រាក់បានឡើយ ។

## ជំពូកទី ៧

## បទបញ្ញត្តិអវសាន

មាត្រា ៦២. - បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយពីច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

ច្បាប់នេះរដ្ឋសភា នៃរដ្ឋកម្ពុជាបានអនុម័តនៅថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ១៩៩១ នាសម័យប្រជុំសាមញ្ញលើកទី ២១ នីតិកាលទី ១ ។

ភ្នំពេញ ថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ១៩៩១

ជ. រដ្ឋសភា

ប្រធាន

ហត្ថលេខា និង ត្រា : ជា ស៊ីម

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

អគ្គលេខាធិការក្រុមប្រឹក្សារដ្ឋ

ចាន់ វ៉ែន